**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

ថ្ងៃព្រហស្បតិ៍ ៣កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០

# លិខិតផ្សព្វផ្សាយស្តីពីការអញ្ជើញចូលរួមដេញថ្លៃ លើការផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ

រដ្ឋបាលរាជធានីភ្នំពេញ កំពុងស្វែងរកនូវក្រុមហ៊ុនដែលមានសមត្ថភាព បទពិសោធន៍ និងហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាម និងសំណល់រឹងនៅរាជធានីភ្នំពេញ ក្រោមដំណើរការ និងនីតិវិធីលទ្ធកម្មតាមលក្ខណៈស្តង់ដារអន្តរជាតិ។ ក្នុងដំណើរការលទ្ធកម្មនេះ នឹងត្រូវធ្វើឡើងជា០២ដំណាក់កាលផ្សេងគ្នា ក្នុងនោះក្រុមហ៊ុនដែលទទួលបានការជ្រើសរើស ក្នុងដំណាក់កាលទី១ នឹងមានសិទ្ធិចូលរួមដេញថ្លៃបន្ត ក្នុងដំណាក់កាលទី២ (ដំណាក់កាលលទ្ធកម្ម)។ រាជធានីភ្នំពេញ ត្រូវបានចែកចេញជា០៣តំបន់ សម្រាប់ឱ្យក្រុមហ៊ុនធ្វើការជ្រើសរើសក្នុងការផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទៅតាមតំបន់នីមួយៗ។ លិខិតអញ្ជើញនៃការដាក់ពាក្យស្នើសុំដេញថ្លៃត្រូវប្រកាសផ្សព្វផ្សាយជាសាធារណៈដល់ក្រុមហ៊ុនក្នុងស្រុក ក្រុមហ៊ុនអន្តរជាតិ និងក្រុមហ៊ុនបណ្តាក់ទុនរួមគ្នាទាំងអស់។

សម្រាប់ព័ត៌មានទូទៅ និងការទទួលបាននូវឯកសារនៃការដាក់ពាក្យដេញថ្លៃដំបូង (ដំណាក់កាលទី១) មានដូចខាងក្រោម៖

១. សម្រាប់ព័ត៌មាន និងការទទួលបាននូវឯកសារ (Hardcopy) នៃការដេញថ្លៃដំបូង ដំណាក់កាលទី១ (Prequalification documents) សូមធ្វើការទំនាក់ទំនង៖
   - សាលារាជធានីភ្នំពេញ
   - លោក នួន សំណាវុធ អភិបាលរង្វាកស្វយ័តគ្រប់គ្រងសំរាម សំណល់រឹង រាជធានីភ្នំពេញ
   - ទូរស័ព្ទ: +៨៥៥ ១៧ ៧២២ ២២៨ និងអ៊ីម៉ែល: nuon_samnavuth@phnompenh.gov.kh

២. រាល់ឯកសារនៃការដាក់ពាក្យស្នើសុំ និងឯកសារព័ត៌មានពាក់ព័ន្ធទៅនឹងការដេញថ្លៃដំបូង ដំណាក់កាលទី១ (Prequalification documents) អាចទាញយកបានតាមរយៈគេហទំព័ររបស់រដ្ឋបាលរាជធានីភ្នំពេញ www.phnompenh.gov.kh។

៣. កាលបរិច្ឆេទទទួលពាក្យស្នើសុំចូលរួមដេញថ្លៃ ត្រូវបានកំណត់ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ១៦:០០ (ម៉ោងនៅរាជធានីភ្នំពេញ)។

៤. ទីកន្លែងទទួលពាក្យស្នើសុំ៖ នៅសាលារាជធានីភ្នំពេញ ទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថាន ជាន់ទី៧ អគារលេខ៦៩ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

៥. រដ្ឋបាលរាជធានីភ្នំពេញ នឹងរៀបចំសន្និសីទ ស្តីពីដំណើរការ និងនីតិវិធីនៃការចូលរួមដេញថ្លៃដំបូង (ដំណាក់កាលទី១) នៅថ្ងៃទី១២ ដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ៩ព្រឹក នៅសាលប្រជុំជាន់ទី១១ សាលារាជធានីភ្នំពេញ។

៦. រាល់ឯកសារនៃការដាក់ពាក្យស្នើសុំអាចផ្ញើតាមរយៈប្រៃសណីយ៍ ឬអាចដាក់ដោយផ្ទាល់តាមអាសយដ្ឋានរបស់រដ្ឋបាលរាជធានីភ្នំពេញខាងលើ។ រដ្ឋបាលរាជធានីភ្នំពេញមិនទទួលខុសត្រូវរាល់ការបាត់បង់ ឬយឺតយ៉ាវនៃការដាក់ពាក្យស្នើសុំទេ។

៧. រដ្ឋបាលរាជធានីភ្នំពេញរក្សាសិទ្ធិក្នុងការទទួល ឬមិនទទួលនូវឯកសារនៃការដាក់ពាក្យស្នើសុំ ដែលមានការយឺតយ៉ាវ។

៨. រដ្ឋបាលរាជធានីភ្នំពេញ មិនទទួលខុសត្រូវចំពោះរាល់ការចំណាយទាំងឡាយក្នុងការដាក់ពាក្យស្នើសុំរបស់ក្រុមហ៊ុនទេ។

៩. រដ្ឋបាលរាជធានីភ្នំពេញ នឹងធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុនដែលនឹងទទួលបានការជ្រើសរើស និងមិនបានជ្រើសរើស ក្នុងដំណាក់កាលទី១នេះ។

ទទួលបានលិខិតអញ្ជើញនេះ សូមបណ្តាក្រុមហ៊ុនក្នុងស្រុក ក្រុមហ៊ុនអន្តរជាតិ និងក្រុមហ៊ុនបណ្តាក់ទុនរួមគ្នាទាំងអស់ ដែលមានចំណាប់អារម្មណ៍លើការដេញថ្លៃនេះ សូមប្រញាប់ធ្វើការទំនាក់ទំនង និងដាក់ពាក្យស្នើសុំឱ្យបានទាន់ពេលវេលាកំណត់។

៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៨៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

KINGDOM OF CAMBODIA
NATION RELIGION KING

PHNOM PENH CAPITAL HALL

No: ✓ PPCH

Phnom Penh, February 25, 2020

# Invitation for Prequalification

## PHNOM PENH MUNICIPAL SOLID WASTE MANAGEMENT PROJECT

## Contract No. PPCA/PPMSWM/ 01-03
## Collection and Transportation of Solid Waste in Phnom Penh City

1. The Phnom Penh Capital Administration (PPCA) is seeking to award contracts for the Collection and Transportation of Solid Waste in Phnom Penh City (the Contract)) under an international competitive bidding process. For this purpose, the Phnom Penh City will be divided into three (3) Zones and Contracts will be awarded Zone-wise. The procurement process will follow a two stage bidding procedure under which prospective bidders will be prequalified under the 1st stage. In the 2nd stage the bid documents will be issued to only prequalified bidders in Stage 1.

2. The PPCA intends to prequalify firms for the three Contracts and invites interested Applicants to submit applications for Prequalification.

3. The Invitation for Prequalification is open to all eligible national and international Applicants, including Joint Ventures and Consortiums.

4. It is expected that the Invitation for Bids will be issued in **late April 2020** to those Applicants who have met all the qualification requirements specified in the Prequalification Document.

5. To obtain further information and to receive a copy of the Prequalification Document, prospective Applicants should contact:

   **The Phnom Penh Capital Administration**
   Contact Person: *Mr. Nuon Samnavuth*
   Title: *Director, Solid Waste Management Authority*
   Telephone No.: *+85517 722 228*
   Email Address: nuon_samnavuth@phnompenh.gov.kh
   Website: *www.phnompenh.gov.kh*

6. Prospective Applicants may download the Prequalification Document from PPCA website or write to the above address requesting for the **Prequalification Document for Contract No. PPCA/PPMSWM/01-03: Collection and Transportation of Solid Waste in Phnom Penh City**.

7. The Prequalification Applications must be submitted **on or before 1600 Hours, Phnom Penh Time on 31 March 2020** at the address given below:

   **The Phnom Penh Capital Administration**
   Waste Management and Environment Division
   7th Floor, Phnom Penh Capital Hall
   #69, Preah Monivong Blvd, Sangkat Srah Chak, Khan Daun Penh
   Phnom Penh, Cambodia

8. A Prequalification Conference will be held in Phnom Penh on March 12-13, 2020 at 9.00 am on the 11th Floor, Phnom Penh City Hall at the address shown above.

9. The completed Prequalification Documents can be sent by post/courier or submitted in person. No liability will be accepted by the PPCA for loss or late delivery.

10. The PPCA reserves the right to accept or reject late Applications.

11. The PPCA will not be responsible for any costs or expenses incurred by Applicants in connection with the preparation or delivery of their Prequalification Applications.

12. The PPCA will notify Applicants who have been prequalified or not qualified in writing.